## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សារលិខិតរំលែកមរណទុក្ខ

**ផ្ញើជូន**

**លោកជំទាវ គាត កុលណើ ព្រមទាំងក្រុមគ្រួសារ**

**លោកជំទាវ ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន !**

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួល រន្ធត់តក់ស្លុត និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឯកឧត្តម សាន់ សារ៉ាន ទីប្រឹក្សារាជរដ្ឋាភិបាល** ដែលត្រូវជាស្វាមីរបស់**លោកជំទាវ** បានទទួលមរណភាពនាថ្ងៃសុក្រ ១១កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃ៣ ខែតុលា ឆ្នាំ២០២៥ វេលាម៉ោង ១៨:៣៦នាទី ក្នុងជន្មាយុ៨១ឆ្នាំ ដោយពេគាពាធ។

មរណភាពរបស់**ឯកឧត្តម សាន់ សារ៉ាន** មិនត្រឹមតែជាការបាត់បង់នូវស្វាមី ដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា និងជាការបាត់បង់ឪពុក ឪពុកក្មេក និងជីតា ដែលប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗ និងចៅៗប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់ដ៏ធំធេងនូវឥស្សរជនដ៏ល្អឆ្នើមមួយរូប ដែលបានលះបង់អស់កម្លាំងកាយ ប្រាជ្ញាស្មារតី ដើម្បីបុព្វហេតុ **ជាតិ សាសនា ព្រះមហាក្សត្រ** គ្រប់កាលៈទេសៈ ព្រមទាំងបានរួមចំណែកជាមួយរាជរដ្ឋាភិបាលចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយ **លោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់**ឯកឧត្តម សាន់ សារ៉ាន** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ គាត កុលណើ ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃសៅរ៍ ១២កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**